section 2.6.qxp 12/16/2004 3:15 PM Page 1



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

បញ្ហាពីរដែលមានទំនាក់ទំនងគ្នាយ៉ាងសំខាន់ក្នុងការអប់រំនាពេលបច្ចុប្បន្នគឺភាពក្រីក្រ និង និរន្តរភាពអភិវឌ្ឍន៍។ នៅក្នុងផ្នែកនេះនឹងធ្វើការពិនិត្យឧបសគ្គផ្សេងៗ ដូចជា ភាពក្រីក្របង្កភាពរាំងស្ទះដល់ការអប់រំសំរាប់ទាំងអស់គ្នាដែលជាប្រព័ន្ធអភិវឌ្ឍន៍ដ៏សំខាន់ក្នុងការធ្វើឲ្យប្រសើរឡើង និងមាននិរន្តរភាពសំរាប់គុណភាពជីវិតរស់នៅរបស់មនុស្សគ្រប់រូប។ ការស្វែងយល់ពីអ្វីដែលកំពុងកើតមានឡើងចំពោះកត្តាសំខាន់ៗទាំងនេះគឺជាការងារដ៏សំខាន់សំរាប់មនុស្សដែលកំពុងសរសេរព័ត៌មានអំពីអប់រំ។

កង្វះខាតធនធានគឺជាបញ្ហាធំបំផុតតែមួយគត់របស់ប្រព័ន្ធអប់រំភាគច្រើននៅលើសកលលោក និងជាឧបសគ្គរាំរ៉ៃរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ភាពក្រីក្ររបស់គ្រួសារ និងតម្រូវការបញ្ជូនកូនទៅធ្វើការរកកំរៃនៅតែជាមូលហេតុដ៏ចំបងដល់ការរីកចំរើនរបស់អប់រំសំរាប់ទាំងអស់គ្នា។

**ឧទាហរណ៍ទី ១: "កុមារចំនួន ២៥០លាននាក់ធ្វើការ" ទំព័រ ៨។**
**ការអប់រំនៅពេលបច្ចុប្បន្ន**

**ទស្សនាវដ្ដីព័ត៌មានពីផ្នែកអប់រំរបស់** UNESCO

នៅពេលឪពុករបស់ខ្លួនក្លាយទៅជាអ្នកស្រវឹងស្រា ជំពាក់បំណុល និងមិនអាចរកការងារធ្វើបាន កុមារVeeramallu Kesaboina Biksham អាយុ ១១ ឆ្នាំ រស់នៅក្នុងប្រទេសឥណ្ឌាបានឈប់រៀន ហើយទៅធ្វើការងារដោយប្រើកំលាំងពលកម្មធ្ងន់ធ្ងរ។

នេះពុំមែនជាករណីតែមួយគត់ដែលទើបកើតឡើងនោះទេ។ យោងទៅតាមអង្គការពលកម្មអន្តរជាតិមានកុមារអាយុពី ៥ ទៅ ១៧ ឆ្នាំ ជាង ២៥០ លាននាក់ កំពុងធ្វើការងារនៅជុំវិញពិភពលោកនាពេលបច្ចុប្បន្ន ។ ការនេះបញ្ជាក់ថា កុមារម្នាក់ក្នុងចំណោមកុមារ ៦ នាក់កំពុងធ្វើការដោយមិនបានរៀនសូត្រនៅតាមសាលា ពោលគឺមានចំនួនជិត ៣ភាគ៤ (១៨០ លាននាក់) ធ្វើការមិនត្រឹមតែអាចមានគ្រោះថ្នាក់ដល់សុខភាពរបស់កុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្រោះថ្នាក់ដល់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់កុមារផងដែរ។

អ្វីដែលគួរឲ្យបារម្ភទៀតនោះគឺ ឧបត្តហេតុនេះកំពុងតែកើនឡើងឥតឈប់ឈរ។ ឧទាហរណ៍ ចំនួនកុមារធ្វើការកំពុងកើនឡើង ១២ ភាគរយ តាមតួលេខពីមជ្ឈមណ្ឌលទំនាក់ទំនង និងអភិវឌ្ឍន៍។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

លោក Abhimanyu Singh ប្រធានអង្គភាពតាមដានត្រួតពិនិត្យការអនុវត្តក្របខ័ណ្ឌសកម្មភាពក្រុងដាការបស់អង្គការ UNESCO និយាយថា រដ្ឋាភិបាលនៃប្រទេសមួយចំនួនកំពុងគេចខ្លួនចេញពីការដោះស្រាយបញ្ហាពលកម្មកុមារ ដោយសារពលកម្មកុមារជាបញ្ហានយោបាយសេដ្ឋកិច្ច សង្គមកិច្ចដ៏ស្មុគស្មាញ។ លោកពោលបន្តទៀតថា ប្រការដែលសំខាន់នោះគឺថា កុមារទាំងអស់មានសិទ្ធិទទួលការអប់រំ។ ដូចនេះ ប្រសិនបើយើងចង់សំរេចកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា យើងត្រូវតែយកចិត្តទុកដាក់ដោះស្រាយបញ្ហាពលកម្មកុមារឲ្យបានជោគជ័យជាមុនសិន។

បញ្ហានេះពុំមែនកើតឡើងដូចគ្នានៅគ្រប់តំបន់ទាំងអស់ជុំវិញពិភពលោកនោះទេ។ កុមារធ្វើការភាគច្រើនរស់នៅតាមតំបន់អាស៊ីប៉ាស៊ីហ្វិក (៦០ ភាគរយនៃចំនួនកុមារសរុបនៅលើពិភពលោក ឬ ១២៧ លាននាក់មានអាយុក្រោម ១៤ ឆ្នាំ)។

មានកុមារធ្វើការចំនួនប្រហែល ៤៨ លាននាក់ក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា និងប្រហែល ១៧ លាននាក់ក្នុងតំបន់អាមេរិកឡាទីន និងការាប៊ៀន។ ប្រទេសអភិវឌ្ឍន៍មានកុមារធ្វើការ ប្រហែល ២,៥ លាននាក់។

តើស្ថានភាពដ៏អាក្រក់នេះកើតឡើងបណ្តាលមកពីមូលហេតុអ្វី ? លោក Alphones Tay មន្ត្រីផ្នែកអប់រំកុមារតូចរបស់អង្គការ UNESCO និយាយថា មូលហេតុចំបងគឺបណ្តាលមកពីកង្វះធនធាន និងឆន្ទៈនយោបាយដើម្បីដោះស្រាយបញ្ហាពលកម្មកុមារ។ លោកពោលទៀតថា យើងកំពុងតែព្យាបាលរោគសញ្ញាតែប៉ុណ្ណោះ ដោយមិនបានដោះស្រាយមូលហេតុដើមនៃបាតុភូតដែលបណ្តាលមកពីដំណើរការមិនប្រក្រតីរបស់សង្គមឡើយ។

រដ្ឋាភិបាលកំពុងទទួលរងសម្ពាធឲ្យលុបបំបាត់ពលកម្មកុមារ និងបញ្ជូនកុមារទាំងនោះទៅសាលារៀន ដូចជា កម្មវិធីអន្តរជាតិរបស់អង្គការពលកម្មពិភពលោកស្តីអំពីការលុបបំបាត់ពលកម្មកុមារ ដោយមានប្រទេសជាង ៥០ កំពុងធ្វើការលុបបំបាត់ពលកម្មកុមារជាបណ្តើរ ៗ។

រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍កំពុងផ្តល់ជំរើសអប់រំដល់កុមារពលកម្ម ដូចជា សាលាពេលយប់។ ឧទាហរណ៍ នៅស្រុក Rajasthan ប្រទេសឥណ្ឌា កុមារពលកម្មមានចំនួនជាង ១៥០០០ នាក់បានប្រឡងជាប់ចេញពីសាលាយប់មួយឈ្មោះថា Barefoot. ប៉ុន្តែបញ្ហានោះគឺថា តើកុមារម្នាក់ដែលធ្វើការខ្លាំងពេញមួយថ្ងៃមានកំលាំងកាយចិត្តរៀនដែរឬទេ?

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

**ឧទាហរណ៍ទី ២: ភាពខុសគ្នាខាងទ្រព្យសម្បត្តិ និងការទទួលការអប់រំ**

*ប្រភព : របាយការណ៍អំពីស្ថានភាពប្រជាជនពិភពលោកឆ្នាំ ២០០២: មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន*

ការចុះឈ្មោះចូលរៀន និងភាពជោគជ័យលើការអប់រំមានលក្ខណៈខុសគ្នាអាស្រ័យលើទ្រព្យធន ជាពិសេស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែគម្លាតមានការខុសគ្នាស្រឡះ។ កុមារអាយុពី ៦ ទៅ ១៤ ឆ្នាំនៃគ្រួសារដែលមានទ្រព្យសម្បត្តិច្រើនបំផុតចំនួន ២០ ភាគរយចុះឈ្មោះកូនឲ្យចូលរៀននៅក្នុងសាលាច្រើនជាងកុមារដែលមកពីគ្រួសារក្រីក្របំផុត ៤០ ភាគរយនៅក្នុងប្រទេសស្ទើរតែទាំងអស់។

ភាពខុសគ្នារវាងគ្រួសារអ្នកមាន និងអ្នកក្រមានទំហំធំ (ច្រើនជាង ៤៥ ភាគរយ) នៅក្នុងប្រទេសអាហ្វ្រិកខាងលិច ដូចជា ប្រទេសបែនីន ប្រទេសប៊ីគីណាហ្វាសូ ប្រទេសម៉ាលី និងសឺណេកាល់ និងក្នុងប្រទេសម៉ូរ៉ូកូ និងប៉ាគីស្ថាន។ ផ្ទុយទៅវិញ គេឃើញមានភាគរយនៃការចុះឈ្មោះចូលរៀនខុសគ្នាបន្តិចបន្តួចនៅក្នុងប្រទេសកែនយ៉ា ម៉ាឡាវី កាហ្សាក់ស្ថាន និងអូបេគីស្ថាន។

កំរិតសំរេចជោគជ័យលើការសិក្សាក៏បង្ហាញឲ្យឃើញពីភាពខុសគ្នាខាងទ្រព្យសម្បត្តិដែលមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតផងដែរ។ ឧទាហរណ៍ ភាពខុសគ្នាក្នុងប្រទេសឥណ្ឌារវាងគ្រួសារអ្នកមានបំផុត ២០ ភាគរយ និងគ្រួសារអ្នកក្របំផុត គឺមានចំនួន ១០ ឆ្នាំ (បើពិនិត្យទៅលើចំនួនឆ្នាំចូលរៀនក្នុងសាលារបស់កុមារអាយុពី ១៥ ទៅ ១៩ ឆ្នាំ) ចំណែកប្រទេសតាន់ហ្សានៀរគឺមានចំនួនតែពីរឆ្នាំប៉ុណ្ណោះ។

ក្នុងប្រទេសមួយចំនួន កុមារក្នុងគ្រួសារក្រីក្រភាគច្រើនពុំបានទទួលការសិក្សាឡើយ។

ការសិក្សានាពេលថ្មីៗក្នុងប្រទេសចំនួន ៣៥ នៅអាហ្វ្រិកខាងលិច និងកណ្តាល និងអាស៊ីខាងត្បូងបង្ហាញថា កុមារមានអាយុ ១៥ ទៅ ១៩ ឆ្នាំចំនួនពាក់កណ្តាល ឬច្រើនជាងពាក់កណ្តាលនៅក្នុងប្រទេសចំនួន ១០មិនបានរៀនចប់ថ្នាក់ទី ១ ឡើយ។

section 2.6.qxp 12/16/2004 3:15 PM Page 4



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

កិច្ចព្រមព្រៀងអន្តរជាតិមួយដែលមានជាយូរមកហើយចែងថា ការអប់រំបឋមសិក្សាគួរតែមានលក្ខណៈជាសកលមកដល់ដើមសតវត្សរ៍ទី ២១។ គម្លាតនៃការចូលរៀនរវាងកុមារមកពីគ្រួសារមានព្រទ្យសម្បត្តិ និងគ្រួសារក្រីក្របញ្ជាក់ថា ចំនួនកុមារមកពីគ្រួសារក្រីក្រមិនបានសំរេចគោលដៅអប់រំបឋមសិក្សាច្រើនជាងកុមារមកពីគ្រួសារមានទ្រព្យសម្បត្តិ។

ប្រទេសមួយចំនួនបានសំរេចគោលដៅនៃការអប់រំបឋមសិក្សាដោយការលើកកំពស់ការចុះឈ្មោះចូលរៀនក្នុងចំណោមគ្រួសារក្រីក្រ។ ឧទាហរណ៍ជាង៧០ ភាគរយនៃជោគជ័យរបស់សកលកម្មអប់រំបឋមសិស្សានៅប្រទេសកូឡុំប៊ី ប៉េរូ និងហ្វីលីពីនត្រូវបានផ្តល់ទៅឲ្យកុមារមកពីគ្រួសារក្រីក្រ។ មានប្រទេសកំពុងអភិវឌ្ឍន៍តិចតួចណាស់ដែលគ្រួសារអ្នកមានមិនបានសំរេចសកលកម្មអប់រំបឋមសិក្សា។

នៅប្រទេសដែលបានជ្រើសរើសសំរាប់ការសិក្សាស្រាវជ្រាវមួយដោយសាវីសមភាពគិតជាតួលេខអំពីបរិក្ខា និង បរិស្ថានក្នុងសាលារៀន ធ្វើឲ្យកុមារអាយុពី ៦ដល់ ១៤ ឆ្នាំក្នុងគ្រួសារក្រីក្រចុះឈ្មោះចូលរៀនតិចជាងកុមារក្នុងគ្រួសារអ្នកមាន។



section 2.6.qxp 12/16/2004 3:15 PM Page 5



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

### មូលហេតុបង្កឲ្យមានគម្លាត

តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឲ្យមានអត្រាទាបនៃការចុះឈ្មោះចូលរៀន និងលទ្ធផលនៃការអប់រំមិនបានល្អក្នុងចំណោមសិស្សក្រីក្រ?

ទាំងនេះទាក់ទងនឹងការផ្តល់សេវាកម្ម និងតម្រូវការរៀនសូត្ររបស់កុមារក្រីក្រ។ សិស្សក្រីក្ររស់នៅឆ្ងាយពីសាលារៀន។ សាលារៀនភាគច្រើនសាងសង់នៅតាមទីប្រជុំជន និងតំបន់ទាំងឡាយណាដែលមានគ្រួសារអ្នកមានរស់នៅ។ ឧទាហរណ៍ សិស្សត្រូវចំណាយពេលវេលា ៤៥ នាទីដើម្បីធ្វើដំណើរទៅកាន់សាលាបឋមជិតបំផុតនៅតំបន់ជនបទនៃប្រទេសហ្គីនេ ប៉ុន្តែកុមារក្នុងតំបន់ទីប្រជុំជនចំណាយពេលតែ ១៩ នាទីប៉ុណ្ណោះដើម្បីធ្វើដំណើរទៅសាលារៀន។

ប៉ុន្តែការមាន ឬគ្មានសាលារៀននៅជិតភូមិពុំមែនជាបញ្ហាចំបងនៅក្នុងប្រទេសជាច្រើនឡើយ ។

ការចំណាយទៅលើការអប់រំបានកើនឡើងនៅតាមកន្លែងជាច្រើនក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែការកើនឡើងលើការចំណាយដោយមិនបានយកចិត្តទុកដាក់ ជាពិសេសទៅលើតម្រូវការរបស់សិស្សក្រីក្រអាចជួយបន្ថែមគម្លាតកាន់តែធំថែមទៀត។

ភស្តុតាងពីប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបង្ហាញថា ភាគរយដ៏ច្រើននៃការចំណាយរបស់រដ្ឋសំរាប់អប់រំគឺសំរាប់តែសកម្មភាពរដ្ឋភិបាល ដែលភាគច្រើនផ្តល់ផលប្រយោជន៍ដល់អ្នកមាន។ នៅអាមេរិកឡាទីន ភាពខុសគ្នានៃការទទួលការអប់រំគឺបណ្តាលមកពីកង្វះប្រសិទ្ធភាពនៃប្រព័ន្ធសាលារៀនរដ្ឋដែលជាសាលារបស់សិស្សក្រីក្រ និងបណ្តាលមកពីការចំណាយតិចតួចទៅលើការអប់រំបឋមសិក្សា និងមធ្យមសិក្សាគឺជាប្រភេទសាលាផ្តល់ប្រយោជន៍ដល់សិស្សក្រីក្រយ៉ាងច្រើន។ បើទោះបីរដ្ឋាភិបាលលៃលកដាក់ធានធានឲ្យបានគ្រប់គ្រាន់ដើម្បីលើកកំពស់លទ្ធភាព និងឱកាសចូលរៀនរបស់សិស្សក្រីក្រ និងគុណភាពអប់រំសំរាប់សិក្សក្រីក្រក៏ដោយ ក៏រដ្ឋាភិបាលនៅតែអាចខ្វះសមត្ថភាព រដ្ឋបាលក្នុងការផ្តល់សេវាកម្មនានាបំរើផលប្រយោជន៍ប្រជាជនផងដែរ។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

វិបត្តិផ្សេងៗដូចជាសង្គ្រាម សង្គ្រាមស៊ីវិល វិបត្តិសេដ្ឋកិច្ច និងបញ្ហាជំងឺឆ្លងរារាំងដល់ការផ្តល់សេវាអប់រំ និងការចូលរៀនរបស់សិស្ស។ នៅក្នុងអតីតប្រទេសយូកូស្លាវី និងអាស៊ីកណ្តាល អត្រាចុះឈ្មោះចូលរៀនសំរាប់ការអប់រំមូលដ្ឋានមានកំរិតទាបយ៉ាងខ្លាំងនៅចុងទសវត្សរ៍ ១៩៩០។ បញ្ហាទាំងនេះពិតជាបង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសិស្សក្រីក្រ។

គុណភាពអប់រំដែលរួមមានកម្មវិធីសិក្សា សៀវភៅសិក្សា វិធីសាស្ត្របង្រៀន ការបណ្តុះបណ្តាលគ្រូ អាត្រាផលធៀបគ្រូ–សិស្ស និងការចូលរួមរបស់មាតាបិតាសិស្សក្នុងការកំណត់លទ្ធផលអប់រំ ដូចជា ការបន្តរៀនសូត្រនៅសាលារបស់សិស្ស កំរិតនៃការសំរេចជោគជ័យក្នុងការរៀនសូត្ររបស់សិស្ស និងពិន្ទុប្រលងរបស់សិស្ស។

ឧទាហរណ៍ ការសិក្សាស្រាវជ្រាវនៅអាហ្វ្រិកខាងត្បូងបង្ហាញថា អត្រាផលធៀបគ្រូ–សិស្សមានឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនឆ្នាំនៃការបញ្ចប់ការសិក្សារបស់សិស្ស។ នៅអ៊ីហ្ស៊ីប អត្រាសិស្សឈប់រៀនមានទំនាក់ទំនងទៅនឹងកត្តាគុណភាពសាលា និងបរិយាកាសរៀនសូត្រក្នុងសាលា។ សិស្សប្រុស និងសិស្សស្រីត្រូវការបរិយាកាសសាលាផ្សេងគ្នា។

នៅប្រទេសមួយចំនួន ការថយចុះនៃអត្រាកំណើតទារកក៏ជួយកាត់បន្ថយសម្ពាធទៅលើប្រព័ន្ធអប់រំរដ្ឋដែរ គឺផ្តល់ឱកាសលើកកំពស់គុណភាពអប់រំ ដោយមិនចាំបាច់បង្កើនការចំណាយឡើយ។

### ស្បៀងសំរាប់ការអប់រំ

កម្មវិធីអាហារសំរាប់ការអប់រំរបស់ប្រទេសបង់ក្លាដែសគឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាអសន្តិសុខស្បៀងក្នុងគ្រួសារ និងបញ្ហាអត្រាសិស្សស្រីចូលរៀនមានចំនួនតិចក្នុងចំណោមគ្រួសារក្រីក្រ។ ចាប់តាំងពីពេលចាប់ផ្តើមនៅឆ្នាំ ១៩៩៣ កម្មវិធីនេះជួយដល់សាលាបឋមសិក្សាប្រហែល ៥០០០ សាលានៅទូទាំងប្រទេស។ កម្មវិធីនេះផ្តល់ស្បៀងមួយចំនួនដែលជាចំណែករបស់កុមារក្នុងជីវភាពរស់នៅរបស់គ្រួសារមានគោលបំណងឲ្យកុមារទាំងនោះអាចទៅសិក្សានៅសាលារៀនបានយូរ។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កត្តះធនធាន

វត្តមានសិស្សចូលរៀនបានកើនឡើង ប៉ុន្តែចំនួនប្រហែល ១០ ទៅ ១៥ ភាគរយគឺជាក្មេងស្រី។ ការអប់រំជួយផ្តល់សិទ្ធិអំណាច និងមានភស្តុតាងបង្ហាញថា យុវវ័យដែលបានទទួលការអប់រំច្រើន ពន្យារពេលរៀបការទៀតផង។

### តម្រូវការ និងផលប្រយោជន៍រំពឹងបាន

តម្រូវការរៀនសូត្រគឺអាស្រ័យទៅលើការរំពឹងបានផលប្រយោជន៍សំរាប់គ្រួសារ ពោលគឺប្រាក់ចំណូលខ្ពស់ក្នុងគ្រួសារដែលកូនបានរៀនសូត្រអាចរកបាន (ប៉ុន្តែក៏ជួយឲ្យមានសុខភាពល្អ និងមានកូនតិចផងដែរ)។ តាមការប៉ាន់ស្មានពីការសិក្សាមួយបង្ហាញឲ្យឃើញថា អ្នកមានការអប់រំអាចមានប្រាក់ចំណូលកើនឡើងជាមធ្យមចំនួន ១០% សំរាប់ការសិក្សាបន្ថែមក្នុងមួយឆ្នាំ។ បើពួកគេមានឱកាសរៀនសូត្របន្ត។

នៅប្រទេសមួយចំនួន ការរំពឹងបានផលប្រយោជន៍ពីការអប់រំមានកំរិតទាប ដោយសារមូលហេតុផ្សេងៗ ដោយនាំឲ្យតម្រូវការលើការអប់រំនៅក្នុងចំណោមសិស្សក្រីក្រធ្លាក់ចុះ។ នៅអាហ្វ្រិកឡាទីន កត្តាទាំងអស់នោះរួមមាន តម្លៃនៃការអប់រំ គុណភាពអន់ក្នុងសាលារៀនរដ្ឋ និងការរើសអើងប្រឆាំងនឹងក្រុមជនជាតិភាគតិច ឬក្រុមប្រើភាសាផ្សេង និងការរើសអើងប្រឆាំងនឹងស្ត្រីក្នុងទីផ្សារការងារ។

ផ្ទុយទៅវិញ ផលប្រយោជន៍ដែលបានមកពីការអប់រំនៅអាស៊ីខាងកើត និងប្រទេសមួយចំនួននៃអាស៊ីខាងត្បូងនៅមានតម្លៃខ្ពស់ដោយសារតែការធ្វើវិនិយោគទុនក្នុងការលើកកំពស់បច្ចេកវិទ្យា និង ការគាំទ្រលើការនាំចេញ ព្រមទាំងគោលនយោបាលដែលផ្តល់ផលប្រយោជន៍ផ្សេងៗទៀត និងការគាំទ្រដល់ការអប់រំនៅក្នុងគ្រួសារ។

កម្មវិធីជួយកាត់បន្ថយការចំណាយលើការអប់រំរបស់សិស្សក្រីក្រអាចលើកកំពស់តម្រូវការនៃការអប់រំរបស់គ្រួសារក្រីក្របាន។ ឧទាហរណ៍ កម្មវិធី PROGRESA ក្នុងប្រទេស ម៉ិចសិចកូ ដែលផ្តល់ជំនួយឧបត្ថម្ភបន្ថែមទៅឲ្យគ្រួសារក្រីក្រជាការប្តូរឲ្យកូនទៅរៀនទៀងទាត់បានកាត់បន្ថយអាត្រាឈប់រៀន និងជួយឲ្យសិស្សឡើងថ្នាក់បានច្រើន។

C·O·L

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

សិស្សក្នុងសាលាមិនអាចរៀនបានឡើយ បើក្រពះរបស់គេស្រេកឃ្លាន ហើយប្រសិនបើគ្រូមិនមកបង្រៀនទៀងទាត់ និងសមស្រប។ តាមស្ថានភាពពិភពលោកបច្ចុប្បន្ន ការផ្តល់ការអប់រំប្រកបដោយគុណភាពនៅក្រោមដើមឈើទំនងជាមិនអាចធ្វើបានឡើយ ប្រសិនការងារសាលាយកមកធ្វើនៅផ្ទះត្រូវតែធ្វើនៅពេលយប់មានពន្លឺតិចៗ ឬបន្ទាប់ពីធ្វើស្រែចំការពេញមួយថ្ងៃ។

យើងបានពិនិត្យមើលរួចហើយនូវឧទាហរណ៍ទាក់ទងនឹងបញ្ហានៃភាពក្រីក្រជះឥទ្ធិពលទៅលើការអប់រំ និងពិនិត្យថាតើ ភាពក្រីក្រមានផលប៉ះពាល់យ៉ាងណាដល់វត្តមានរបស់សិស្សនៅក្នុងសាលា ប៉ះពាល់ដល់គុណភាព និងលទ្ធផលរៀនសូត្ររបស់សិស្ស។ ប៉ុន្តែតើប្រព័ន្ធព័ត៌មានគួរចូលរួមដោះស្រាយបញ្ហាទាំងនេះបានយ៉ាងដូចម្តេច ?

នៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ភាពក្រីក្រមានវិសាលភាពធំធេងណាស់។ ក្នុងស្ថានភាពនេះទោះបីជាប្រព័ន្ធផ្សព្វផ្សាយខិតខំបំពេញតួនាទីក្នុងការផ្សព្វផ្សាយអំពីវិស័យអប់រំយ៉ាងណាក៏ដោយក៏គេមិនសង្ឃឹមថាបានលទ្ធផលល្អប្រសើរដែរ ព្រោះថា ទោះបីជាគោលនយោបាយល្អយ៉ាងណាក៏ដោយ ក៏គេត្រូវការប្រាក់ដើម្បីយកទៅអនុវត្តគោលនយោបាយនោះដែរ។ បើគ្មានប្រាក់ទេគោលនយោបាយនោះក៏មិនអាចក្លាយជាការពិតបានឡើយ។ ប្រទេសក្រីក្រទាំងនោះមានឱកាសតិចណាស់ក្នុងការទទួលប្រាក់ពីថវិកាជាតិដែលមានបន្តិចបន្តួចនោះ។

ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលគេបានឃើញគំរូមួយចំនួននៅក្នុង CD ROM នេះថា គេអាចសំរេចបានលទ្ធផលមួយចំនួនដោយការចំណាយប្រាក់បន្តិចបន្តួច។ ទោះបីជាការវិនិយោគផ្នែកហិរញ្ញវត្ថុគឺជាលក្ខខណ្ឌដំបូងនៃការប្រែក្លាយប្រទេសពីកំពុងអភិវឌ្ឍន៍ទៅជាប្រទេសអភិវឌ្ឍន៍ក៏ដោយ ក៏ប្រទេសជាច្រើនចាប់ផ្តើមឡើងពីការវិនិយោគបន្តិចបន្តួច។ ការជះលុយទាំងដុំៗទៅលើបញ្ហាពុំមែនជាដំណោះស្រាយនោះទេ។

ការយកចិត្តទុកដាក់ផ្សព្វផ្សាយរឿងដែលគួរឲ្យរន្ធត់ទាក់ទងនឹងបញ្ហាអប់រំដែលអាចជាដំណឹងនាំមុខនោះអាចជំរុញអាជ្ញាធរ ក្រុមប្រជាជន និងបុគ្គលពាក់ព័ន្ធឲ្យជួយដោះស្រាយបញ្ហាទាំងនេះ។ ដូចនេះជាការសំខាន់បំផុត ប្រព័ន្ធសារព័ត៌មានត្រូវផ្សព្វផ្សាយអំពីការខិតខំប្រឹងប្រែងទាំងឡាយដែលបានអនុវត្តក្នុងកាលៈទេសៈដ៏លំបាក។ ការផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីសំរេចលទ្ធផលជាកត្តាសំខាន់ជាពិសេសនៅក្នុងប្រទេសដែលមានបញ្ហាច្រើន និងដែលកំពុងប្រឈមមុខគ្រោះថ្នាក់ដោយសារពលរដ្ឋរបស់ខ្លួនកំពុងអស់សង្ឃឹម។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

កង្វះខាតគ្រូបង្រៀនគឺជាបញ្ហារាំរ៉ៃមួយក្នុងប្រព័ន្ធអប់រំទាំងឡាយក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ហើយជាបញ្ហាដ៏សំខាន់ដែលបណ្តាញព័ត៌មានគួរធ្វើការអង្កេត។ នេះគឺជាប្រភពបញ្ហាដែលរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និងសាលារៀនត្រូវស្វែងរកវិធីដោះស្រាយទាំងអស់គ្នា។

រដ្ឋាភិបាលនៃប្រទេសជាច្រើនកំពុងចាត់វិធានការការពារជាមុន ដោយធ្វើការទាក់ទាញមនុស្សឲ្យកាន់តែច្រើនឡើងដើម្បីធ្វើជាគ្រូបង្រៀន រដ្ឋាភិបាលខ្លះកំពុងបញ្ចុះបញ្ចូលគ្រូចូលនិវត្តឲ្យវិលត្រឡប់មកប្រព័ន្ធអប់រំវិញ និងខ្លះទៀតជ្រើសរើសម្តាយឪពុកសិស្ស ឬសិស្សស្ម័គ្រចិត្តដើម្បីបំពេញកង្វះខាតគ្រូបង្រៀន។ តើរដ្ឋាភិបាល ឬសហគមន៍របស់អ្នកកំពុងធ្វើអ្វីដែរដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀននេះ?

ការសិក្សាបានបង្ហាញឲ្យឃើញថា ការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ក្នុងថ្នាក់រៀនអាស្រ័យទៅលើគុណភាពនៃការបណ្តុះបណ្តាលគ្រូ ព្រមទាំងអាកប្បកិរិយា និងចំណង់ចំណូលចិត្ត។

ការបណ្តុះបណ្តាលគ្រូ និងការផ្តល់ការអប់រំ ក្នុងថ្នាក់រៀនគឺជាផ្នែកមួយដ៏សំខាន់ដែលត្រូវស្វែងយល់ឲ្យបានច្បាស់លាស់។ អ្វីដែលកំពុងកើតឡើងជាក់ស្តែងនោះគឺជាខ្លឹមសារនៃសាច់រឿងដែលទាក់ទងនឹងចំណាប់អារម្មណ៍របស់មនុស្ស និងកំពុងស្វែងយល់ពីលទ្ធផលដោយពិនិត្យទៅលើឧទាហរណ៍ឲ្យបានច្រើនទៅតាមកាលៈទេសៈផ្សេង ក៏ដូចជាការស្វែងយល់ព័ត៌មានមិនល្អអំពីបរិយាកាសមិនសមរម្យ និងគ្រូបង្រៀនពុំសូវមានទឹកចិត្តផងដែរ។

សូម្បីតែព័ត៌មានមិនល្អក៏មានដំណឹងល្អតិចតួចដែរ ដូចជា ដំណើរការរីកចំរើនជាបណ្តើរៗក្នុងការលើកកំពស់ធនធានក្នុងថ្នាក់រៀន។ នៅអាហ្វ្រិកខាងត្បូង រដ្ឋាភិបាលបន្ទាប់ពីរបបអាផាថេតបានធ្វើការពិនិត្យសាលាយ៉ាងល្អិតល្អន់ និងបង្កើតឲ្យមានបញ្ជីតម្រូវការរបស់សាលា (School Register of Needs) ដើម្បីប្រើជាវិធានធ្វើផែនការ និងជាចំណុចផ្តើមដើម្បីទ្រទ្រង់ការរីកចំរើននៅពេលអនាគត។ ការត្រួតពិនិត្យលើកដំបូងបានបង្ហាញឲ្យឃើញបញ្ហាគួរឲ្យភ្ញាក់ផ្អើលមួយចំនួន ហើយការត្រួតពិនិត្យលើកទីពីរបង្ហាញឲ្យឃើញការរីកចំរើនដែលបានសំរេចនៅក្នុងកាលៈទេសៈលំបាកៗ ដែលជាក្តីសង្ឃឹមនៅទីបញ្ចប់ផងដែរ។

section 2.6.qxp 12/16/2004 3:16 PM Page 10



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

សារព័ត៌មានប្រចាំសប្តាហ៍ធំបំផុតរបស់អាហ្វ្រិកខាងត្បូង ឈ្មោះថាសារព័ត៌មានសាន់ដេថែម ធ្វើការជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដើម្បីស្វែងរកសាលារៀនក្រីក្រដែលបានទទួលលទ្ធផលគួរឲ្យភ្ញាក់ផ្អើល និងផ្តល់រង្វាន់ដល់សាលាទាំងនោះ។ បន្ទាប់ពីបោះពុម្ពផ្សាយពីសមិទ្ធិផលសាលាទាំងនោះទទួលបានកេរ្តិ៍ឈ្មោះ និងទទួលថវិកាសំរាប់សាលាពីផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាលបន្ថែមទៀត។

**ឧទាហរណ៍ទី ៣ : ព័ត៌មានល្អ និងមិនល្អនៅតាមសាលានៅអាហ្វ្រិកខាងត្បូង**

ព័ត៌មានអប់រំរបស់សារព័ត៌មានថែម ទីក្រុងឡុងដ៍

ដោយ Karen MacGregor

ខែធ្នូ ២០០១

ការសិក្សាថ្នាក់ជាតិលើកទីពីរក្នុងសាលានៅអាហ្វ្រិកខាងត្បូងបានបង្ហាញឲ្យឃើញពីការរីកចំរើនសំខាន់ៗលើការបែងចែកសេវាអប់រំសំខាន់ៗដែលអនុវត្តឡើងដោយរដ្ឋាភិបាលក្រោយរបបអាផាថេត ប៉ុន្តែក៏នៅតែមានភាពមិនស្មើគ្នាផងដែរ។ សាលារាប់ម៉ឺនខ្នងនៅតែគ្មានទឹក អគ្គីសនីទូរស័ព្ទ ឬបង្គន់អនាម័យ ហើយសាលាមួយក្នុងចំណោមសាលាបីទទួលរងការរំខានពីសកម្មភាពមិនស្របច្បាប់។

យោងតាម "ការចុះផ្សាយពីបញ្ជីតម្រូវការសាលា" នាពេលថ្មីៗដែលបានស្រាវជ្រាវសាលារដ្ឋ និងឯកជនចំនួន ២៧១៤៨ សាលា កាលពីខែឧសភាដល់ ខែធ្នូ ឆ្នាំ ២០០០ បានឲ្យដឹងថា សាលាចំនួន ៣៩០ និងសាលាបច្ចេកទេសចំនួន ១៥២ ត្រូវការជំនួយជាចាំបាច់។

ការសិក្សានេះក៏បានរកឃើញផងដែរថា មានសាលាចំនួន ៤១៤ ខ្នងនៅឆ្នាំ ២០០០ ច្រើនជាងចំនួនសាលានៅឆ្នាំ ១៩៩៦ ដែលជាឆ្នាំសិក្សាស្រាវជ្រាវជាតិលើកទី ១ ហើយរកឃើញទៀតថាសាលាទាំងនោះមានការរីកចំរើនយ៉ាងខ្លាំង បើពិនិត្យពីចំនួនសិស្សក្នុងថ្នាក់រៀន និងសេវាអប់រំមូលដ្ឋាន។ លោក Kader Asmal រដ្ឋមន្ត្រីអប់រំបានសរសេរថា និន្នាការនេះពិតជាកើតឡើងយ៉ាងពិតប្រាកដ ប៉ុន្តែតម្រូវឲ្យធ្វើការងារច្រើនថែមទៀត។

ចំនួនសាលាដែលមានបង្គន់អនាម័យបានកើនឡើងពី ៤៥% ទៅ ៨៣% ទូរស័ព្ទពី៤០% ទៅ ៦៤% អគ្គីសនីពី៤២% ទៅ ៥៧% និងទឹកពី៦៥% ទៅ៧២%។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

ចំនួនសិស្សមានការថយចុះចំនួន ២,៣ % ក្នុងរយៈពេល ៤ ឆ្នាំនេះ ជាពិសេសនៅក្នុងសាលាបឋមសិក្សា (ដែលមានប្រហែល ៦២% នៃសាលាទាំងអស់) ។ យោងតាមមូលហេតុដែលអះអាងដោយសាលាតូចៗមួយចំនួន ការធ្លាក់ចុះនេះអាចបណ្តាលមកពីការធ្លាក់ចុះនៃចំនួនសាលាបឋមសិក្សាចំនួន ៦១០ និងមធ្យមសិក្សាចំនួន ៣៧៤។

មានបន្ទប់សិក្សាចំនួន ៣០៧៩៣ នៅឆ្នាំ ២០០០ ច្រើនជាងបន្ទប់សិក្សានៅឆ្នាំ ១៩៩៦ និងដោយសារចំនួនសិស្សធ្លាក់ចុះធ្វើឲ្យមាន ចំនួនសិស្សតិចនៅក្នុងថ្នាក់រៀន។ ក្នុងឆ្នាំ ២០០០ អត្រាសិស្សជាមធ្យមធៀបនឹងថ្នាក់រៀនគឺ ៣៨:១ តិចជាង ឆ្នាំ ១៩៩៦ ដែលមានចំនួន ៤៣:១ ហើយចំនួនសាលាខ្វះបន្ទប់រៀនត្រូវបានគេរាយការណ៍ថាបានធ្លាក់ចុះ ១០%។

អត្រាផលធៀបសិស្ស–គ្រូគឺនៅដដែល ៣២:១ ពោលគឺក្រៅពីការធ្លាក់ចុះចំនួនសិស្ស ចំនួនគ្រូបានថយចុះពី ៣៧០៦០០ នៅឆ្នាំ ១៩៩៦ ទៅ ៣៦៦០០០ នៅឆ្នាំ ២០០០។ ផ្ទុយទៅវិញ សាលាឯកជនមានអាត្រាផលធៀបសិស្ស–គ្រូ ពី ១:១៥។

ការសិក្សានៅឆ្នាំ ២០០០ បានពិនិត្យមើលទៅលើសកម្មភាពខុសច្បាប់ និងសន្តិសុខក្នុងសាលារៀនជាលើកដំបូង ហើយបានរកឃើញថា សាលាមួយក្នុងចំណោមសាលា ៣ (៩៦៥៤) បានទទួលរងការរំខានពីសកម្មភាពខុសច្បាប់ផ្សេងៗនៅឆ្នាំ ១៩៩៩ ដែលមាន ៩៧២ ករណីគឺជាទង្វើខុសច្បាប់ធ្ងន់ធ្ងរ ដូចជា ការរំលោភ ការចាក់ដោយអាវុធ ឬការធ្វើឃាត។ សកម្មភាពខុសច្បាប់ដែលកើតឡើងញឹកញាប់បំផុតមាន អំពើចោរកម្ម ដែលមានសាលាចំនួន ៣០%ទទួលរងនូវការលួចសំភារៈពី ១ ទៅ ៥ ដង។

ការស្រាវជ្រាវនោះបានសន្និដ្ឋានថា ទោះបីសាលាមានការរីកចំរើនយ៉ាងខ្លាំងក្នុងរយៈពេល ៤ ឆ្នាំក៏ដោយ ក៏មានសាលាជាច្រើននៅតែជួបប្រទះការខ្វះខាត ហើយខ្វះសុវត្ថិភាព និង សន្តិសុខ ខ្វះការថែទាំសាលា និងលទ្ធភាពប្រើបច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មាន គឺជាប្រការចាំបាច់។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

នៅមុនឆ្នាំ ១៩៩៦ ប្រព័ន្ធអប់រំពុំមានភាពច្បាស់លាស់ឡើយ ហើយប្រព័ន្ធអប់រំនៅពេលនោះទទួលរងឥទ្ធិពលពីជាតិសាសន៍ ទ្រព្យសម្បត្តិ និងតំបន់។ ការសិក្សានានាត្រូវបានធ្វើឡើងដើម្បីស្វែងយល់អំពីចំនួនហេដ្ឋារចនាសម្ព័ន្ធជាប្រយោជន៍បង្កើត "មូលដ្ឋានព័ត៌មានសមរម្យមួយ"សំរាប់ធ្វើផែនការ ផ្តល់សេវាអប់រំឲ្យបានដល់សាលាទាំងអស់ និងសំរាប់ធ្វើការប៉ាន់ស្មានលើការរីកចំរើន និង និន្នាការផ្សេងៗ។

លោកសាស្ត្រចារ្យ Asmal បាននិយាយថា "ការរកឃើញពីការស្រាវជ្រាវផ្តល់ភស្តុតាងច្បាស់លាស់ថា យុទ្ធសាស្ត្រលុបបំបាត់ភាពអយុត្តិធ៌មអាផាថេតមានលទ្ធផលវិជ្ជមាន។" លោកពោលបន្ថែមទៀតថា ក្រសួងរបស់លោកនឹងធ្វើការខិតខំប្រឹងប្រែងថែមទៀតដើម្បីលុបបំបាត់វិសមភាពតាមរយៈការយកចិត្តទុកដាក់លើការធ្វើឲ្យសាលាក្រីក្រកាន់តែល្អប្រសើរ។

***ឧទាហរណ៍ទី ៤***<br>
***ខែកញ្ញា ឆ្នាំ ១៩៩៩***<br>
***សាលាល្អ***<br>
***របាយការណ៍រៀបចំឡើងដោយ* Philippa Garson, *អ្នកនិពន្ធសារព័ត៌មានគ្រូបង្រៀន ន្ត***<br>
***រូបភាពដោយលោក* Andrzej Sawa**

ជាថ្មីម្តងទៀត ការសិក្សាពីសាលាល្អបានរកឃើញប្រព័ន្ធអប់រំដ៏ល្អនៅអាហ្វ្រិកខាងត្បូង និងទទួលស្គាល់ជាពិសេសចំពោះសាលាទាំងឡាយណាដែលបានទទួលលទ្ធផលល្អបំផុត។

សាលាមធ្យមសិក្សា Mathunjwa ដែលជាសាលាជនបទនៅតំបន់ KwaZulu-Natal បានទទួលរង្វាន់ Liberty Life-Sunday Times ចំពោះស្នាដៃល្អលើការអប់រំ និងទទួលបានទឹកប្រាក់ចំនួន ៥០០០០ R. រង្វាន់ជាទឹកប្រាក់ចំនួន ១០០០០ R សំរាប់សាលាមួយបានដល់ សាលា St. Boniface នៅ Northern Cape សាលាមធ្យមសិក្សា Inkamana នៅ KwaZulu-Natal សាលាមធ្យមសិក្សា Glen Cowie នៅខេត្ត Northern និងសាលា មធ្យមសិក្សា Buhlehuthu នៅ KwaZulu-Natal.

section 2.6.qxp 12/16/2004 3:16 PM Page 13



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

ការសិក្សានោះបង្ហាញថា ការអប់រំដែលមានគុណភាពខ្ពស់នៅតាមកន្លែងផ្សេងៗនៅទូទាំងប្រទេស កំពុងកើតមានរូបរាងឡើង។ គំនិតច្នៃប្រឌិតថ្មីៗកំពុងត្រូវបានគេដាក់បញ្ចូលទៅក្នុងវិស័យអប់រំ ដូចជា ការប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃធនធានសំរាប់វិស័យអប់រំ ការគ្រប់គ្រងមិនល្អក្នុងថ្នាក់រៀន ឬការធ្វើឲ្យបរិយាកាសរៀនសូត្រមានភាពសប្បាយរករាយ។

សាលារៀនកំពុងតែស្វែងរកវិធីសាស្ត្រថ្មីៗក្នុងការនាំការសិក្សាឲ្យទៅជិតពិភពពិត ពោលគឺសាលាទាំងអស់នោះកំពុងយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍន៍បំណិនជីវិតដែលជាជំនាញដ៏សំខាន់ក្នុងការលើកកំពស់ឱកាសការងាររបស់សិស្សសំរាប់ជីវភាពរស់នៅ។ ចំពោះសាលាណាដែលមានលទ្ធភាពអាចផ្តល់កម្មវិធីអភិវឌ្ឍន៍បំណិនជីវិតសំរាប់សិស្ស សាលានោះនឹងធ្វើឲ្យសិល្ប:ជីវិតរបស់សិស្សឲ្យមានភាពរស់រវើកក្នុងយុគសម័យកុំព្យូទ័របច្ចុប្បន្ន។ តន្ត្រី ល្ខោន និងសិល្ប:សំដែងផ្សេងៗ កំពុងមានប្រជាប្រិយភាពនៅតាមសាលាឯកជន និង សាលារដ្ឋផងដែរ។

ពេលសាលាកំពុងព្យាយាមរត់តាមការវិវត្តន៍បច្ចេកវិទ្យាកុំព្យូទ័រ មានតែសាលារៀនទេដែលមានធនធានគ្រប់គ្រាន់អាចឈានទៅរកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដូចជា អ៊ីនធើណែត និងអ៊ីមែលសំរាប់បំរើគោលបំណងអប់រំ។

ទោះយ៉ាងនេះក៏ដោយ ក៏សាលាមួយចំនួនពុំមានលទ្ធភាពបំពាក់បច្ចេកវិទ្យាបែបនេះដែរ ដែលជាសញ្ញាបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា គម្លាតរវាងសាលាដែលមានបំពាក់បច្ចេកវិទ្យា និងគ្មានបំពាក់បច្ចេកវិទ្យាមានទំហំធំឡើងៗ។ ផ្ទុយទៅវិញ សាលាដែលគ្មានបំពាក់បច្ចេកវិទ្យាជាច្រើនក៏នៅតែអាចមានលទ្ធភាពផ្តល់ការអប់រំប្រកបដោយគុណភាពបានដែរ ដោយគ្រាន់តែដោះស្រាយបញ្ហាកង្វះធនធាន ដូចជា ធនធានមនុស្ស។ ការស្រាវជ្រាវនោះបញ្ជាក់ថា សាលាមួយចំនួនធំនៅតែអាចផ្តល់សេវាអប់រំបានល្អប្រសើរ បើទោះបីសាលាទាំងនោះមានធនធានតិចតួចក្តី។

ចម្លើយតបទៅនឹងការអង្កេតឆ្នាំនេះមានទ្រង់ទ្រាយធំធេងគួរឲ្យចាប់អារម្មណ៍ខ្លាំង។ សាលាជាច្រើនទទួលបានបណ្ណសរសើរថាជាសាលាល្អជាងគេ ហើយបានដាក់តាំងបណ្ណសរសើរទាំងនោះនៅតាមការិយាល័យធ្វើការ។ លទ្ធផលនេះគួរថ្លែងអំណរគុណដល់ការអង្កេតដែលបានដាក់សាលាឆ្នើមជាងគេទាំងនោះតាម "ក្រុមសាលាឆ្នើម"។

សាលាដែលមិនសូវមានធនធាន តែបានចូលក្នុងក្រុមសាលាឆ្នើមបានទាក់ទាញសាជីវកម្ម និងអ្នកផ្តល់ជំនួយជាច្រើន បានផ្តល់ជំនួយហិរញ្ញវត្ថុ និងអាហារូបករណ៍ដល់សិស្ស។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.១ កង្វះធនធាន

លោក Mthembeni Mbatha នាយកសាលាមធ្យមសិក្សា Mathunjwa និយាយថា ការដាក់បញ្ចូលក្នុងបញ្ជីសាលាឆ្នើមបានធ្វើឲ្យសាលារបស់លោកមានការប្រែប្រួលយ៉ាងខ្លាំង។ នៅឆ្នាំនេះសាលារបស់លោកបានទទួលពាក្យសុំអាហារូបករណ៍ចំនួន ៤។ លោកគិតថា ការសិក្សាអំពីសាលាឆ្នើមគឺជាសកម្មភាពដ៏ល្អ ហើយសាលាទាំងអស់គួរចូលរួមសហការ។ ចំណាត់ថ្នាក់ក្នុងបញ្ជីសាលាឆ្នើមគឺជាគោលបំណងរបស់សាលា ហើយសាលាទាំងនោះចង់ឲ្យខ្លួនស្ថិតនៅក្នុងបញ្ជីសាលាឆ្នើមផងដែរ ព្រមទាំងជួយលើកទឹកចិត្តកែលំអគុណភាពនៃការអប់រំទៀតផង។

លោក Inkamana នាយកសាលាមធ្យមសិក្សា Isabel Steenkamp និយាយថា ការមានឈ្មោះក្នុងបញ្ជីសាលាឆ្នើមនៅឆ្នាំ ១៩៩៨ បានជួយឲ្យកូនសិស្សក្នុងសាលារបស់លោកទទួលបានអាហារូបករណ៍។

ផ្ទុយទៅវិញ សាលាកាតូលិកជាច្រើនដែលតែងតែផ្តល់សេវាអប់រំបានល្អ និងមានលទ្ធភាពទទួលលទ្ធផលនៃការអប់រំបានដ៏ប្រសើរ បើទោះបីមានធនធានតិចតួចក៏ដោយ តែមិនបានចូលរួមសហការណ៍ឡើយ។ ការសិក្សាពីសាលាឆ្នើមទទួលការរិះគន់ពីសាលាទាំងឡាយណាដែលយល់ឃើញថា ការសិក្សានោះបង្កឲ្យមានចំណុចអវិជ្ជមានលើការប្រកួតប្រជែងក្នុងវិស័យអប់រំ។

លោក Alan Clarke នាយកសាលា Westerford High នៅ Cape Town បានសំដែងគំនិតអភិវក្សរបស់លោកចំពោះការស្រាវជ្រាវនោះ ដោយលោកនិយាយថា ការសិក្សានោះប្រហែលជាពុំមែនកំពុងធ្វើអ្វីមួយដែលខ្លួនកំពុងធ្វើឡើយ។ យើងពុំមានបំណងធ្វើការប្រកួតប្រជែងគ្នាឡើយ។ យើងត្រូវការកិច្ចសហការ និងធ្វើការរួមគ្នា។

លោក Penny Vinjevold អ្នកសំរបសំរួលការសិក្សាស្រាវជ្រាវសាលាឆ្នើមនិយាយថា សាលាមួយចំនួនសំរេចចិត្តមិនចូលរួម ដោយសារសាលាទាំងនោះយល់ថា ការសិក្សាបានធ្វើការប្រៀបធៀបគោ និងក្របី។ សាលាខ្លះទៀតអះអាងថា ការសិក្សានោះជំរុញឲ្យមានការប្រកួតប្រជែងដែលមិនចាំបាច់ ហើយមិនឆ្លុះបញ្ចាំងពីតម្លៃ និងរូបភាពពិតរបស់សាលាឡើយ។ នៅឆ្នាំនេះលក្ខខណ្ឌរបស់យើងគឺសមិទ្ធិផលនៃការអប់រំ និងការបន្ថែមតម្លៃទៅលើការអប់រំ ពោលគឺយើងស្វែងរកសាលាទាំងឡាយណាដែលសំរេចលទ្ធផលល្អប្រសើរ និងមានសកម្មភាពបន្ថែមជាច្រើនទៀត ដូចជាសកម្មភាពអប់រំសីលធម៌ក្រៅម៉ោងជាដើម។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

ការលុបបំបាត់ភាពក្រីក្រ
ទឹក និងអាម័យ
និរន្តរភាពផលិតកម្ម និងការប្រើប្រាស់
ថាមពល
សារធាតុគីមី
ការគ្រប់គ្រងធនធានធម្មជាតិ
ការទទួលខុសត្រូវលើសុខភាព
និរន្តរភាពអភិវឌ្ឍន៍នៅអាហ្វ្រិក
មធ្យោបាយអនុវត្តន៍
ក្របខ័ណ្ឌសកម្មភាពតាមស្ថាប័នសំរាប់និរន្តរភាពអភិវឌ្ឍន៍

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### ការលុបបំបាត់ភាពក្រីក្រ

នៅមុន ឬត្រឹមឆ្នាំ ២០១៥ កាត់បន្ថយឲ្យបានជាងពាក់កណ្តាលនៃចំនួនប្រជាជនពិភពលោកដែលរកប្រាក់ចំណូលបានតិចជាង ១ ដុល្លារក្នុងមួយថ្ងៃ ហើយកាត់បន្ថយឲ្យបានជាងពាក់កណ្តាលនៃចំនួនមនុស្សដែលខ្វះសន្តិសុខស្បៀង (*តាមការបញ្ជាក់អះអាងឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*)។

នៅមុន ឬត្រឹមឆ្នាំ ២០១៥ ធានាសំរេចការរីកចំរើនដ៏ប្រសើរនៃជីវិតរស់នៅតាមតំបន់អាណាធិបតេយ្យយ៉ាងតិចបំផុត ១០០ លាននាក់ ដូចដែលបានស្នើឡើងក្នុងគំនិតផ្តួចផ្តើម "ទីក្រុងគ្មានតំបន់អាណាធិបតេយ្យ" (*តាមការបញ្ជាក់អះអាង ឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*)។

បង្កើតឲ្យមានមូលនិធិសាមគ្គីពិភពលោកដើម្បីលុបបំបាត់ភាពក្រីក្រ និងដើម្បីលើកកំពស់ការអភិវឌ្ឍន៍សង្គម និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

កំណត់ចំណាំ : បញ្ជីអភិវឌ្ឍន៍គោលដៅសហស្សវត្សរ៍ពុំបានលើកឡើងពីការប្តេជ្ញាចិត្តឲ្យបានទូលំទូលាយឡើយ ប៉ុន្តែបញ្ជីនេះផ្តល់ព័ត៌មានអំពីការប្តេជ្ញាចិត្តសំខាន់ ដែលបានដាក់ចេញនៅក្នុងការអនុវត្តន៍ផែនការ Johannesburg។ បើចង់ស្វែងយល់អំពីខ្លឹមសារអត្ថបទពេញលេញនៃការប្តេជ្ញាចិត្តនានា សូមបើកគេហទំព័រ: www.johannesburgsummit.org

### ទឹក និងអនាម័យ

នៅមុន ឬត្រឹមឆ្នាំ ២០១៥ កាត់បន្ថយឲ្យបានចំនួនពាក់កណ្តាលនៃប្រជាជនពិភពលោកដែលគ្មានទឹកស្អាតប្រើប្រាស់ (*តាមការបញ្ជាក់អះអាងឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*)។

នៅមុន ឬត្រឹមឆ្នាំ ២០១៥ កាត់បន្ថយឲ្យបានពាក់កណ្តាលនៃប្រជាជនពិភពលោកដែលរស់នៅដោយគ្មានអានាម័យ។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### និរន្តរភាពផលិតកម្ម និងការប្រើប្រាស់ផលិតផល

ជំរុញ និងលើកកំពស់ការអភិវឌ្ឍន៍ តាមក្របខណ្ឌកម្មវិធី ១០ ឆ្នាំ ដើម្បីបង្កើនល្បឿនផ្លាស់ប្តូរឆ្ពោះទៅរកការផលិត និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

### ថាមពល

### ថាមពលដែលអាចកកើតឡើងដោយខ្លួនឯង

ធ្វើការផ្លាស់ប្តូរការផ្គត់ផ្គង់ថាមពល និងលើកកំពស់ថាមពលប្រកបដោយចីរភាពនូវការចែករំលែកប្រភពថាមពល ដែលអាចកកើតឡើងដោយខ្លួនឯងដើម្បីលើកកំពស់ការចូលរួមវិភាគទានដល់ការផ្គត់ផ្គង់ថាមពលទាំងអស់។

### លទ្ធភាពនៃការប្រើប្រាស់ថាមពល

លើកកំពស់លទ្ធភាពប្រើប្រាស់សេវាកម្ម និងធនធានថាមពលដែលអាចទុកចិត្តបាន មានតម្លៃថោក អាចឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ច អាចទទួលយកបានក្នុងសង្គម និងមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន ពោលគឺសេវា និងធនធានថាមពលគ្រប់គ្រាន់ដើម្បីធ្វើឲ្យសំរេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍រួមបញ្ចូលទាំងគោលដៅកាត់បន្ថយពាក់កណ្តាលនូវចំនួនប្រជាជនក្រីក្រដែល គ្មានថាមពលប្រើប្រាស់នៅមុន ឬត្រឹមឆ្នាំ ២០១៥។

### ទីផ្សារថាមពល

លុបបំបាត់ការបំភ្លៃសព័ត៌មានទីផ្សារថាមពល ដោយរួមបញ្ចូលទាំងការកែទំរង់រចនាសម្ព័ន្ធពន្ធដារ និងបំបាត់ការបញ្ចុះតម្លៃថមពលមិនសមស្របដោយរដ្ឋាភិបាល។

គាំទ្រដល់ការខិតខំប្រឹងប្រែងដើម្បីលើកកំពស់មុខងារ តម្លាភាព និងព័ត៌មានអំពីទីផ្សារថាមពលដែលទាក់ទងនឹងការផ្គត់ផ្គង់ និងតម្រូវការក្នុងគោលបំណងធ្វើឲ្យមានស្ថិរភាពកាន់តែប្រសើរឡើង និងដើម្បីធានាឲ្យអ្នកប្រើប្រាស់មានលទ្ធភាពប្រើសេវាថាមពលគ្រប់គ្រាន់។

C·O·L

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### សមត្ថភាពប្រើថាមពល

បង្កើតកម្មវិធីក្នុងស្រុកដើម្បីបង្កើនសមត្ថភាពប្រើថាមពលអគ្គីសនីដោយមានសហគមន៍អន្តរជាតិគាំទ្រ។ បង្កើនល្បឿនអភិវឌ្ឍន៍ និងផ្សព្វផ្សាយសមត្ថភាពប្រើថាមពល និងបច្ចេកវិទ្យា អភិរក្សថាមពលដោយបញ្ចូលទាំងការលើកកំពស់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ថមពលបន្ថែមទៀត។

### សារធាតុគីមី

នៅមុន ឬត្រឹមឆ្នាំ ២០២០ គោលបំណងប្រើប្រាស់ និងកាត់បន្ថយសារធាតុគីមីទៅតាមវិធីទាំងឡាយ ណាដែលមិនបង្កឲ្យប៉ះពាល់អវិជ្ជមានទៅលើសុខភាពមនុស្ស និងបរិស្ថាន។

ពិនិត្យការប្តេជ្ញាចិត្តឡើងវិញដោយធ្វើយ៉ាងណាឲ្យការគ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់មានភាពសមរម្យ។

លើកកំពស់ការផ្តល់សច្ចាប័ន និងអនុវត្តច្បាប់អន្តរជាតិជាតិស្តីពីសារធាតុគីមី និងសំណល់គ្រោះថ្នាក់រួមមានអនុសញ្ញា Rotterdam **និរន្តរភាពផលិតកម្ម និងការប្រើប្រាស់ផលិតផល** ជំរុញឲ្យអនុសញ្ញានេះអាចចូលជាធរមាននៅឆ្នាំ ២០០៣ និងអនុសញ្ញា Stockholm ឲ្យចូលជាធរមាននៅឆ្នាំ ២០០៤។

នៅមុន ឬត្រឹមឆ្នាំ ២០០៥ បង្កើតយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងសារធាតុគីមី ដោយផ្អែកលើសេចក្តីប្រកាស Bahia និងអាទិភាពសំរាប់សកម្មភាពក្រោយឆ្នាំ ២០០០។

ជំរុញប្រទេសនានាឲ្យអនុវត្តប្រព័ន្ធថ្មីដូចៗគ្នានៅលើសកលលោកសំរាប់បែងចែកប្រភេទ និង–ដាក់ផ្លាកសញ្ញាសារធាតុគីមីទាំងឡាយឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដោយធ្វើយ៉ាងណាឲ្យប្រព័ន្ធមួយដូចនោះអាចដំណើរការបានពេញលេញនៅមុន ឬត្រឹមឆ្នាំ ២០០៨។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### ការគ្រប់គ្រងមូលដ្ឋានធនធាន

#### ទឹក

គ្រប់គ្រងធនធានទឹកដោយមានការចូលរួម និងដោយមានផែនការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់នៅមុន ឬត្រឹមឆ្នាំ ២០០៥។

#### សមុទ្រ និងការនេសាទ

ជំរុញឲ្យមានការអនុវត្តវិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ីសំរាប់អភិវឌ្ឍន៍សមុទ្រប្រកបដោយនិរន្តរភាពនៅមុន ឬត្រឹមឆ្នាំ ២០១០។

ដោយឈរលើភាពបន្ទាន់ និងបើអាចធ្វើបាន នៅមុន ឬត្រឹមឆ្នាំ ២០១៥ រក្សា ឬស្តារឡើងវិញនូវស្តុកត្រីដែលបានបាត់បង់ឲ្យបានដល់កំរិតច្រើនបំផុត ដែលអាចផ្តល់ផលខ្ពស់បំផុត និងប្រកបដោយនិរន្តរភាព។ អនុវត្តផែនការសកម្មភាពអង្គការកសិកម្ម និងស្បៀងអាហារទៅតាមកាលបរិច្ឆេទដែលបានឯកភាពគ្នា :

- សំរាប់ការគ្រប់គ្រងសមត្ថភាពធ្វើនេសាទនៅមុន ឬត្រឹមឆ្នាំ ២០០៥ និង
- ដើម្បីទប់ស្កាត់ ស្វែងយល់ និងលុបបំបាត់ការធ្វើនេសាទខុសច្បាប់ និងគ្មានរបាយការណ៍នៅមុន ឬត្រឹមឆ្នាំ ២០០៤។

អភិវឌ្ឍន៍ និងសំរបសំរួលការប្រើប្រាស់វិធីសាស្ត្រ និងវិធានផ្សេងៗ ដែលរួមមានវិធីសាស្ត្រប្រព័ន្ធអេកូឡូស៊ី លុបបំបាត់ការធ្វើនេសាទបែបបំផ្លាញ បង្កើតតំបន់ការពារសមុទ្រឲ្យស្របតាមច្បាប់អន្តរជាតិ និងផ្អែកតាមព័ត៌មានវិទ្យាសាស្ត្រ ដោយរួមមានតំណាង បណ្តាញការងារនៅមុន ឬត្រឹមឆ្នាំ ២០១២។ នៅមុន ឬត្រឹមឆ្នាំ ២០០៤ បង្កើតឲ្យមានវិធានធ្វើ របាយការណ៍ និងវាយតម្លៃស្ថានភាពបរិស្ថានសមុទ្រជាសកលក្រោមក្របខ័ណ្ឌការងាររបស់ អង្គការសហប្រជាជាតិ។

លុបបំបាត់ការបន្ធូរបន្ថយតម្លៃដែលរដ្ឋាភិបាលផ្តល់ឲ្យ ដែលជាកត្តាជួយដល់ការធ្វើនេសាទខុសច្បាប់ និងគ្មានរបាយការណ៍ច្បាស់លាស់។

section 2.6.qxp 12/16/2004 3:16 PM Page 20



# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### បរិយាកាស

សំរួលដល់ការអនុវត្តពិធីសារម៉ុងរ៉េអាលស្តីពីសារធាតុបំផ្លាញស្រទាប់អូសូនដោយធានាឲ្យមានមូលនិធិគ្រប់គ្រាន់សំរាប់ជួសជុលការខូចខាតអូសូន នៅមុន ឬត្រឹមឆ្នាំ ២០០៣ ឬ ២០០៥។

ជួយប្រទេសកំពុងអភិវឌ្ឍន៍ឲ្យមានសមត្ថភាពផ្លាស់ប្តូរសារធាតុបំផ្លាញអូសូននៅមុន ឬត្រឹមឆ្នាំ ២០១០ និងជំរុញឲ្យប្រទេសទាំងនោះអនុវត្តតាមកម្មវិធីលុបបំបាត់សារធាតុបំផ្លាញអូសូនស្របតាមពិធីសារម៉ុងរ៉េអាល។

### ជីវៈចំរុះ

នៅមុន ឬត្រឹមឆ្នាំ ២០១០ ធ្វើឲ្យសំរេចការកាត់បន្ថយអត្រាបាត់បង់ជីវៈចំរុះនាពេលបច្ចុប្បន្ន។

### ព្រៃឈើ

បង្កើនល្បឿនអនុវត្តសំណើរ IPF/IFF សំរាប់ចាត់វិធានការតាមប្រទេសនីមួយៗ និងតាមរយៈភាពជាដៃគូ និងពង្រឹងការខិតខំប្រឹងប្រែងធ្វើរបាយការណ៍ជូនវេទិកាអង្គការសហប្រជាជាតិស្តីពីព្រៃឈើដើម្បីរួមចំណែកដល់ការវាយតម្លៃពីការរីកចំរើននៅមុន ឬត្រឹមឆ្នាំ ២០០៥។

### ការទទួលខុសត្រូវរួម

លើកកំពស់ការទទួលខុសត្រូវរួម និងគណនេយ្យភាពឲ្យបានសកម្មតាមរយៈការអភិវឌ្ឍន៍ឲ្យបានពេញលេញ និងអនុវត្តឲ្យមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀង និងវិធានការអន្តរជាតិគំនិតផ្តួចផ្តើមអន្តរជាតិ និងភាពជាដៃគូរវាង សាធារណៈ និងឯកជន និងច្បាប់ជាតិផ្សេងៗ។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### សុខភាព

លើកកំពស់ការអប់រំសុខភាពក្នុងគោលបំណងធ្វើឲ្យសំរេចការយល់ដឹងពីសារសំខាន់នៃការលើកកំពស់ការយល់ដឹងពីបញ្ហាសុខភាពតាមស្តង់ដាពិភពលោកមួយនៅមុន ឬត្រឹមឆ្នាំ ២០១០។

នៅមុន ឬត្រឹមឆ្នាំ ២០១០ កាត់បន្ថយអត្រាមរណភាពទារក និងកុមារក្រោមអាយុ ៥ ឆ្នាំចំនួន ២ ភាគ ៣ និងអត្រាមរណភាពមាតាចំនួន ៣ ភាគ ៤ នៅក្នុងចំណោមអត្រាស្លាប់របស់មាតាក្នុងឆ្នាំ ២០០០ ( *តាមការ បញ្ជាក់អះអាងឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* )។

កាត់បន្ថយការឆ្លងរាលដាលនៃមេរោគអេដស៍ក្នុងចំណោមបុរស និងស្ត្រីដែលមានអាយុពី ១៥ ទៅ ២៤ ឆ្នាំឲ្យបាន ២៥ ភាគរយ នៅតាមប្រទេសដែលទទួលរងគ្រោះដោយសារមេរោគអេដស៍ខ្លាំងបំផុតនៅមុន ឬត្រឹមឆ្នាំ ២០០៥ និងកាត់បន្ថយឲ្យបាន ២៥ ភាគរយផងដែរនូវជំងឺគ្រុនចាញ់របេង និង ជំងឺផ្សេងៗទៀត ( *តាមការបញ្ជាក់អះអាងឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* )។

### និរន្តរភាពអភិវឌ្ឍន៍នៅតាមប្រទេសកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ

នៅមុន ឬត្រឹមឆ្នាំ ២០០៤ បង្កើតគំនិតផ្តួចផ្តើមសកម្មភាពផ្សេងៗ សំរាប់អនុវត្តកម្មវិធីសកលលោកអំពីការការពារបរិស្ថានសមុទ្រឲ្យរួចផុតពីសកកម្មភាពបំពុលពីដីគោកដើម្បីកាត់បន្ថយទប់ស្កាត់ និងគ្រប់គ្រងសំណល់ និងការបំពុល ព្រមទាំងផលប៉ះពាល់ផ្សេងៗដល់សុខភាព។

បង្កើតគំនិតផ្តួចផ្តើមសកម្មភាពដោយផ្អែកលើសហគមន៍ស្តីពីវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនៅមុន ឬត្រឹមឆ្នាំ ២០០៤។

គាំទ្រសេវាកម្មថាមពលសមស្រប មានតម្លៃថោក និងមិនប៉ះពាល់ដល់បរិស្ថានសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅតាមប្រទេសកំពុងអភិវឌ្ឍន៍តាមកោះតូចៗតាមរយៈការពង្រឹង កិច្ចខិតខំប្រឹងប្រែងផ្គត់ផ្គង់ និងផ្តល់សេវាថាមពលនៅមុន ឬត្រឹមឆ្នាំ ២០០៤។

ពិនិត្យឡើងវិញនូវការអនុវត្តកម្មវិធីសកម្មភាព Barbados សំរាប់ការអភិវឌ្ឍន៍ប្រទេសកំពុងអភិវឌ្ឍន៍ នៅតាមកោះតូចៗនៅឆ្នាំ ២០០៤។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### និរន្តរភាពអភិវឌ្ឍន៍សំរាប់ប្រទេសអាហ្វ្រិក

លើកកំពស់ប្រកបដោយនិរន្តរភាពនូវផលិតភាពកសិកម្ម និងសន្តិសុខស្បៀងអាហារឲ្យស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ជាពិសេសកាត់បន្ថយចំនួនប្រជាជនខ្វះស្បៀងឲ្យមកនៅត្រឹមពាក់កណ្តាលនៅមុន ឬត្រឹមឆ្នាំ ២០១៥។

ជួយប្រទេសនៅអាហ្វ្រិកក្នុងការបង្កើត និងអនុវត្តយុទ្ធសាស្ត្រសន្តិសុខស្បៀងនៅមុន ឬត្រឹមឆ្នាំ ២០០៥។

ជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនៅអាហ្វ្រិកដើម្បីអនុវត្តគោលបំណង NEPAD ស្តីពីថាមពលដែលធានាថា ប្រជាជននៅអាហ្វ្រិកយ៉ាងតិចបំផុត ៣៥ ភាគរយមានអគ្គិសនីប្រើប្រាស់ក្នុងរយៈពេល ២០ ឆ្នាំខាងមុខ ជាពិសេសនៅតំបន់ជនបទ។

### យុទ្ធសាស្ត្រអនុវត្ត

ធានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ កុមារទាំងអស់នឹងអាចបញ្ចប់ការអប់រំបឋមសិក្សា ហើយទាំងក្មេងប្រុស និងក្មេងស្រីមានសិទ្ធិទទួលបានការអប់រំដូចៗគ្នានៅគ្រប់កំរិតទាំងអស់ស្របតាមតម្រូវការជាតិ (*តាមការ បញ្ជាក់អះអាងឡើងវិញនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍*)។

លុបបំបាត់វិសមភាពយេនឌ័រគិតជាតួលេខបឋមសិក្សា និងមធ្យមសិក្សាឲ្យបាននៅមុន ឬត្រឹមឆ្នាំ ២០០៥ (*តាមការបញ្ជាក់អះអាងឡើងវិញនៃក្របខណ្ឌសកម្មភាពក្រុងដាកាស្តីពីអប់រំសំរាប់ទាំងអស់គ្នា*)។

សំណូមពរឲ្យមហាសន្និបាតអង្គការសហប្រជាជាតិពិចារណាលើការអនុម័តការអប់រំរយៈពេលមួយទសវត្ស អំពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយផ្តើមនៅឆ្នាំ ២០០៥។

ចាត់វិធានការជាបន្ទាន់ដើម្បីធានាឲ្យមានការរីកចំរើនលើការបង្កើត និងបកស្រាយយុទ្ធសាស្ត្រថ្នាក់ជាតិសំរាប់និរន្តរភាពអភិវឌ្ឍន៍ និងចាប់ផ្តើមអនុវត្តតាមយុទ្ធសាស្ត្រនោះនៅមុន ឬត្រឹមឆ្នាំ ២០០៥ ឲ្យបាន។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.២ ការប្តេជ្ញាចិត្ត គោលដៅ និងពេលវេលាកំណត់ក្នុងផែនការអនុវត្តក្រុង JOHANNESBURG

### ក្របខ័ណ្ឌសកម្មភាពតាមស្ថាប័នសំរាប់និរន្តរភាពអភិវឌ្ឍន៍

អនុម័តវិធានការថ្មីៗសំរាប់ពង្រឹងការរៀបចំស្ថាប័នដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

លើកកំពស់តួនាទីគណៈកម្មការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលក្នុងនោះរួមមានតួនាទីត្រួតពិនិត្យ តាមដាន លើការវិវឌ្ឍន៍ជឿនលឿនក្នុងការអនុវត្តរបៀបវារៈ ២១ និងពង្រីកទំនាក់ទំនងរវាងការអនុវត្តគំនិតផ្តួចផ្តើមសកម្មភាព និងដៃគូការងារ។

ជួយសំរបសំរួល និងលើកកំពស់ការធ្វើសមាហរណកម្មនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពលើវិស័យបរិស្ថាន និងសេដ្ឋកិច្ចសង្គមកិច្ចឲ្យចូលទៅក្នុងកម្មវិធីការងាររបស់គណៈកម្មការតំបន់អង្គការសហប្រជាជាតិ។

បង្កើតយន្តការសំរបសំរួលអន្តរស្ថាប័នឲ្យមានប្រសិទ្ធភាព តម្លាភាព និងភាពទៀងទាត់សំរាប់ដោះស្រាយបញ្ហាសមុទ្រ និងបញ្ហាតំបន់ឆ្នេរស្របតាមប្រព័ន្ធអង្គការសហប្រជាជាតិ។

ចាត់វិធានការជាបន្ទាន់ដើម្បីធានាឲ្យមានការរីកចំរើនលើការបង្កើត និងបកស្រាយយុទ្ធសាស្ត្រថ្នាក់ជាតិសំរាប់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងចាប់ផ្តើមអនុវត្តតាមយុទ្ធសាស្ត្រនោះនៅមុន ឬត្រឹមឆ្នាំ ២០០៥។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.៣ គោលគំនិតក្នុងសាច់រឿង

### លំហាត់ ១ : សាច់រឿងជោគជ័យ

សាច់រឿងអំពីមនុស្ស និងកន្លែងធ្វើការទាំងឡាយណាដែលបានទទួលជោគជ័យតែងតែធ្វើឲ្យមានការចាប់អារម្មណ៍ពីមនុស្ស ដែលសាច់រឿងជោគជ័យទាំងនោះមិនត្រឹមតែជាគំរូល្អមួយឡើយ តែក៏អាចជាខ្លឹមសារអប់រំដ៏សំខាន់ផងដែរ។

មានឧទាហរណ៍ជាច្រើន ដែលនិយាយថា ពីមនុស្សម្នាក់មិនចូលចិត្តសាលាកាលនៅពីក្មេង ប៉ុន្តែក្លាយទៅជាបណ្ឌិតម្នាក់តាមរយៈការរៀនសូត្រអស់មួយជីវិត ឬនិយាយពីសាលាក្រីក្រ ប៉ុន្តែអាចបណ្តុះបណ្តាលកូនសិស្សជាច្រើននាក់ឲ្យប្រលងជាប់មហាវិទ្យា ឬសាកលវិទ្យាល័យ។

បើទោះបីជាអ្នករស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬអភិវឌ្ឍន៍ក៏ដោយ ក៏អ្នកនៅតែអាចរកបានឧទាហរណ៍ល្អពីសាលា មហាវិទ្យាល័យ ឬពីគំរោងផ្សេងៗដែលគ្រូ និងសិស្សខិតខំប្រឹងប្រែងជំនះរាល់បញ្ហាលំបាកនានា ហើយទទួលបានជោគជ័យ។

ចូរស្វែងរកឲ្យបានឧទាហរណ៍មួយ។ សាលារៀន អធិការសាលា អង្គការក្រៅរដ្ឋាភិបាល ឬអ្នកដែលខិតខំរៀនអស់មួយជីវិតពិតជាផ្តល់ឲ្យអ្នកនូវឧទាហរណ៍មួយយ៉ាងពេញចិត្ត។ ចូរទៅធ្វើទស្សនកិច្ចសិក្សាតាមសាលារៀន មហាវិទ្យាល័យ ហើយសម្ភាសគ្រូ សិស្ស និងមាតាបិតាសិស្ស និង ព្យាយាមស្វែងយល់ថា តើសកម្មភាពណាមួយដែលអ្នកគិតថាជារឿងជោគជ័យសំរាប់យកមកធ្វើជាគំរូឧទាហរណ៍។

បន្ទាប់មក សាកសួរជំនាញការអប់រំ ឬជំនាញការផ្សេងៗទៀតដើម្បីយកសមិទ្ធិផលរបស់ពួកគេទៅកត់ត្រាទុកក្នុងបរិបទជាតិ។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.៣ គោលគំនិតក្នុងសាច់រឿង

### លំហាត់ ២: បរិបទស្ថានភាពរួម

អ្នកបានសិក្សារួចហើយថា " និរន្តរភាពអភិវឌ្ឍន៍ " ទាក់ទងទៅនឹងបញ្ហាសង្គម បរិស្ថាន សេដ្ឋកិច្ច និងអភិវឌ្ឍន៍។ គំនិតនៅទីនេះគឺស្វែងយល់ពីទំនាក់ទំនងមួយចំនួនតាមរយៈសាច់រឿងដើម្បីបញ្ចូលព័ត៌មានទៅក្នុងស្ថានភាពមួយមានលក្ខណៈទូលំទូលាយ និងជំរុញឲ្យអ្នកចូលរួមបង្កើតទំនាក់ទំនងឲ្យបានច្រើនតាមដែលអាចធ្វើបាន។

ពិនិត្យមើលពីបញ្ហាកង្វះខាតគ្រូបង្រៀននៅក្នុងស្រុករបស់អ្នក។ តើមានគ្រូប៉ុន្មាននាក់នៅក្នុងសាលាបឋម និងមធ្យមសិក្សា? តើគួរមានគ្រូប៉ុន្មាននាក់ដើម្បីឲ្យអត្រាផលធៀបគ្រូ-សិស្សមានភាពសមរម្យ ដែលអាចធ្វើឲ្យសំរេចបានគុណភាពអប់រំដែរឬទេ? រដ្ឋាភិបាលរបស់អ្នកស្ទើរតែមានគ្រូជាក់ស្តែង និងចំនួនគ្រូបន្ថែម។ តាមរយៈស្ថិតិដែលអ្នករកឃើញ សូមពិនិត្យមើលថាតើកង្វះខាតពិតប្រាកដស្ថិតត្រង់កន្លែងណា បណ្តាលមកពីមូលហេតុអ្វី? ឧទាហរណ៍ តើនៅកំរិតណា? លើមុខវិជ្ជាអ្វី គណិត វិទ្យាសាស្ត្រ ឬភាសា?

ការពិនិត្យមើលទាំងចំនួនគ្រូ និងនិយាយទៅកាន់ជំនាញការអប់រំដើម្បីស្វែងយល់ថាតើពួកគេចង់មានន័យយ៉ាងណាទាក់ទងនឹងគុណភាពអប់រំ ហើយតើមានទំនាក់ទំនងយ៉ាងដូចម្តេចចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងសមត្ថភាពរបស់ប្រទេសដើម្បីធានានិរន្តរភាពអភិវឌ្ឍន៍។

# ២.៦ ភាពក្រីក្រ និង និរន្តរភាព

## ២.៦.៣ គោលគំនិតក្នុងសាច់រឿង

### លំហាត់ទី ៣ : គណនេយ្យភាព

ការប្តេជ្ញាចិត្តនៅលើឆាកអន្តរជាតិរបស់រដ្ឋាភិបាលនឹងពុំមានប្រយោជន៍អ្វីឡើយ ប្រសិនបើរដ្ឋាភិបាលទាំងនោះពុំមានបំណងគោរពការប្តេជ្ញាចិត្តទេនោះ។

បញ្ហាដ៏ធំមួយនៅកិច្ចប្រជុំកំពូលអន្តរជាតិឆ្នាំ ២០០២ ស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព គឺថាសន្និសីទគួរតែជំរុញឲ្យមានការប្តេជ្ញាចិត្តថ្មីៗទៀតឬយ៉ាងណា នៅពេលរដ្ឋាភិបាលជាច្រើនមិនបានគោរពតាមការប្តេជ្ញាចិត្ត ដែលខ្លួនបានឯកភាពនៅឯមហាសន្និបាតទីក្រុង Rio កាលពីមួយទសវត្សរ៍មុន។

បញ្ហាដ៏សំខាន់មួយនោះគឺថា ក្នុងករណីប្រទេសគ្មានធនធាន ឬគ្មានសមត្ថភាពគ្រប់គ្រាន់ការប្តេជ្ញាចិត្តទាំងឡាយគួរធ្វើ ដូចជា "បញ្ជីប៉ង់ប្រាថ្នា" ដែលរដ្ឋាភិបាលនៃប្រទេសទាំងនោះគួរប្រើជាត្រីវិស័យសំរាប់ដើរ បើទោះបីជារដ្ឋាភិបាលទាំងនោះពុំមានឱកាសអនុវត្តទៅតាមការប្តេជ្ញាចិត្តជាសកលនោះក៏ដោយ។

សូមអានកិច្ចព្រមព្រៀងលើវិស័យអប់រំមួយចំនួន ឬអានទាំងអស់បើអាចអានបាន ដែលបានផ្សព្វផ្សាយ យ៉ាងទូលំទូលាយនៅក្នុងរបៀបវារៈ ២១ ជំពូក ៣៦ *(Refer: 2_6_3-Agenda 21-chapter 36.htm from CD ROM)* និងពិនិត្យមើលថាតើ រដ្ឋាភិបាលរបស់អ្នកឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងនោះបានយ៉ាងដូចម្តេច តើរដ្ឋាភិបានបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួនបានប៉ុន្មានចំណុច ហើយថាតើសកម្មភាពរបស់រដ្ឋាភិបាលនោះគ្រប់គ្រាន់ហើយឬនៅ។ អ្នកក៏នឹងបានទទួលព័ត៌មានល្អជាច្រើនផងដែរ ប្រសិនអ្នកអាន "របាយការណ៍អប់រំជាតិ" *(Refer: 2_6_3_national reports on education..htm from CD ROM)* និងអាចបើកឃើញនៅក្នុងគេហទំព័រនៃគណៈកម្មាធិការអង្គការសហប្រជាជតិសំរាប់និរន្តរភាពអភិវឌ្ឍន៍។